Mekong River Commission Secretariat
P.O. Box 6101, 184 Fa Ngoum Road, Unit 18,
Ban Sithane Neua, Sikhottabong District, Vientiane 01000, Lao PDR
Telephone: (856-21) 263 263 Facsimile: (856-21) 263 264

# ព័ត៌មាន និងតួលេខសំខាន់ៗនៃទន្លេមេគង្គ

- **ទន្លេមេគង្គ គឺជាទន្លេធំជាងគេទី ១០ ក្នុងពិភពលោក និងជាទន្លេ ដែលមានប្រវែងវែងជាងគេនៅអាស៊ីអាគ្នេយ៍។** ទន្លេនេះ គឺជាទីប្រមូលផ្តុំធនធានធម្មជាតិ ដែលមានលក្ខណៈសម្បូរបែប ពិសេសក្នុងបរិមាណដ៏ច្រើន ដូចជា ពពួកត្រីសំខាន់ៗដែលជិតផុតពូជ ដូចជា ត្រីរាជ ដែលមានឈ្មោះបច្ចេកទេស *Pangasianodon gigas* និងត្រីផ្សោតអ៊ីរ៉ាវ៉ាឌី ដែលមានឈ្មោះបច្ចេកទេស *Orcaella brevirostris* ។ មានរុក្ខជាតិជាង ២០.០០០ ប្រភេទ និងត្រីជាង ៨៥០ ប្រភេទ នៅក្នុងអាងទន្លេមេគង្គ ដែលហូរកាត់ផ្ទៃដីសរុប ៧៩៥.០០០ គ.ម$^2$ ចាប់ពីតំបន់ទីជម្រាលភាគខាងកើតនៃខ្ពង់រាបទីបេ រហូតដល់តំបន់ដីសណ្តរទន្លេមេគង្គ។

- **សេដ្ឋកិច្ចនៃតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម កំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស។** ប្រជាពលរដ្ឋជិត ៧០ លាននាក់ រស់ក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម។ តំបន់នេះមានកំណើនប្រជាជនយ៉ាងឆាប់រហ័ស។ ប្រការនេះ កំពុងដាក់សម្ពាធកាន់តែខ្លាំងឡើងមកលើធនធានធម្មជាតិ ដោយសារការទាញយកទឹកមកស្រោចស្រពការធ្វើការកសិកម្ម ការពង្រីក និងការអភិវឌ្ឍទីក្រុង ឧស្សាហកាវូបនីយកម្ម ការផលិតអគ្គិសនី និងផលិតកម្មស្បៀង។ បើទោះបីជាតំបន់នេះមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ហើយរដ្ឋាភិបាលមានផែនការកសាងទំនាក់ទំនងក្នុងតំបន់នេះឱ្យរឹតតែស្អិតរមួតបន្ថែមទៀត ដើម្បីជំរុញលើកកម្ពស់ពាណិជ្ជកម្ម និងសេដ្ឋកិច្ចយ៉ាងណាក៏ដោយ មានប្រជាពលរដ្ឋជាច្រើននាក់ នៅបន្តរស់ក្នុងភាពក្រីក្រ ដោយទទួលបានទឹកស្អាត និងសេវាអនាម័យក្នុងកម្រិតទាប ឱកាសការងារតិចតួច ហើយជារឿយៗ ពួកគេនៅពុំមានស្បៀងអាហារ ឬអគ្គិសនីប្រើប្រាស់ឱ្យបានគ្រប់គ្រាន់នៅឡើយ។ ភាពក្រីក្រធ្ងន់ធ្ងរត្រូវបានសង្កេតឃើញ នៅតាមតំបន់ភូមិសាស្ត្រជាច្រើន។ នៅតាមតំបន់ដែលមានការកាត់បន្ថយភាពក្រីក្រ គម្លាត និងវិសមភាពក្នុងសង្គមនៅបន្តកើតមានជាទូទៅនៅឡើយ។

- **អាងទឹកជ្រៅក្នុងទន្លេមេគង្គអាចមានជម្រៅរហូតដល់ ៩០,៥ ម៉ែត្រ។** អាងទឹក ឬអាងទឹកជ្រៅគឺជាតំបន់ដែលទទួលរងសម្ពាធទឹកពីធម្មជាតិស្ថិតនៅបាតទន្លេ។ សម្ពាធទាំងនេះកើតឡើងជាទៀងទាត់នៅតាមដងទន្លេភាគច្រើន និងអាចស្តែងចេញក្នុងទម្រង់ជាច្រើន ដូចជា សម្ពាធទឹករាក់ កើតឡើងក្នុងរយៈពេលយូរ នៅតាមច្រកដែលមានលំហូរដ៏ល្បាប់ និងសម្ពាធទឹកជ្រៅកើតឡើងរយៈពេលខ្លី នៅក្នុងតំបន់បាតទន្លេដែលសម្បូរថ្មច្រើន។ នៅតាមដងទន្លេមេគង្គ និងតាមដៃទន្លេជាច្រើន តំបន់អាងទឹកទាំងនេះ គឺជាដែនជម្រករដូវប្រាំងដ៏សំខាន់ សម្រាប់ពពួកត្រីក្នុងទន្លេមេគង្គ

សំខាន់ៗជាច្រើន និងជាកន្លែងពងសម្រាប់សត្វជាច្រើនប្រភេទ។ មានការយល់ឃើញថា របាយអាងទឹកជ្រៅបែបនេះ មានឥទ្ធិពលយ៉ាងសំខាន់មកលើបម្រែបម្រួលនៃប្រព័ន្ធភូមិសាស្ត្រ សំខាន់ៗទាំងបី ដែលជួយសម្រួលដល់ការធ្វើចរាចរណ៍ត្រី ក្នុងតំបន់ទន្លេមេគង្គនេះ។

- **ធនធាននេសាទទឹកសាបក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម គឺជាធនធាននេសាទធំជាងគេបង្អស់របស់ពិភពលោក ជាមួយនឹងទិន្នផលប្រមាណជា ៤,៤ លានតោនក្នុងមួយឆ្នាំ** គិតជាតម្លៃសរុបប្រមាណ ១៧ ពាន់លានដុល្លារ។ ប្រជាពលរដ្ឋជាង ៤០ លាននាក់ ( ពីរភាគបីនៃចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម) កំពុងចូលរួមយ៉ាងសកម្ម ក្នុងរបរនេសាទ។ របរនេសាទ ផ្តល់ឱ្យប្រជាពលរដ្ឋរស់នៅក្នុងតំបន់អាងទន្លេនេះនូវប្រូតេអ៊ីន ៥០-៨០% នៃប្រូតេអ៊ីនសរុបដែលបានពីសត្វ។ ធនធាននេសាទទាំងនេះ រួមចំណែក ១៨% នៃ ផសស របស់ប្រទេសកម្ពុជា ដែលជាកម្រិតមួយខ្ពស់ជាងការរួមចំណែកនៃផលិតកម្មស្រូវក្នុងសេដ្ឋកិច្ចរបស់ប្រទេសនេះ។ នៅក្នុងប្រទេសឡាវ តម្លៃនៃធនធាននេសាទមានប្រមាណជាជិត ១៣% នៃ ផសស របស់ប្រទេសនេះ។ បើទោះបីជាមិនសូវជាមានសារៈសំខាន់ចំពោះសេដ្ឋកិច្ចរបស់ជាតិយ៉ាងណាក៏ដោយ វិស័យនេសាទនៃទន្លេមេគង្គក្នុងប្រទេសថៃ និងប្រទេសវៀតណាមបានបន្ថែមនូវទឹកប្រាក់ប្រមាណជា ៥.៥០០ លានដុល្លារដល់ ផសស របស់ប្រទេសទាំងពីរនេះជារៀងរាល់ឆ្នាំ។

- **ការបរិភោគត្រី និងវារីសត្វដទៃទៀត គិតជាមធ្យមមានប្រមាណជាជិត ៦៣គ.ក/ប្រជាជនម្នាក់/ ឆ្នាំ** ពោលគឺខ្ពស់ជាងតួលេខមធ្យមរបស់សកលលោកទាំងមូល ដែលមានត្រឹមតែ ១៩គ.ក/ប្រជាជនម្នាក់/ឆ្នាំ។

- **តំបន់ទន្លេមេគង្គ បានក្លាយជាតំបន់មួយក្នុងចំណោមតំបន់ ដែលមានសកម្មភាពរស់រវើកជាងគេខាងការអភិវឌ្ឍវារីអគ្គិសនី នៅក្នុងពិភពលោកទាំងមូល។** រោងចក្រផលិតវារីអគ្គិសនី ដែលមានសមត្ថភាពផលិតអគ្គិសនីបានជាង ៦.៤០០ មេហ្គាវ៉ាត់ ត្រូវបានកសាងនៅតាមប្រព័ន្ធដៃទន្លេក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ក្នុងរយៈពេល ២០ ឆ្នាំ ចុងក្រោយនេះ។ តំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម មានសក្តានុពលអាចផលិតវារីអគ្គិសនីបានរហូតទៅដល់ ៣០.០០០ មេហ្គាវ៉ាត់ ហើយគិតមកដល់បច្ចុប្បន្ននេះ មានការផលិតបានត្រឹមតែ ២៥% នៃសក្តានុពលពេញលេញនេះតែប៉ុណ្ណោះ។ នៅតាមតំបន់ភាគច្រើននៃតំបន់អាងទន្លេមេគង្គ ការប្រើប្រាស់អគ្គិសនីអាចមានត្រឹមតិចជាង ៥% នៃបរិមាណអគ្គិសនី ដែលប្រើប្រាស់ក្នុងប្រទេសឧស្សាហកម្មតែប៉ុណ្ណោះ។ គម្រោងដែលអាចផលិតបានប្រមាណ ៥.៣០០ មេហ្គាវ៉ាត់បន្ថែមទៀត កំពុងស្ថិតនៅក្នុងដំណាក់កាលសាងសង់នៅឡើយ នៅតាមដៃទន្លេក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាង

ក្រោម ។ គេអាចសាងសង់គម្រោងទំនប់វារីអគ្គិសនីចំនួន ១១ នៅតាមដងទន្លេមេ ក្នុងប្រទេសឡាវ ប្រទេសឡាវ-ប្រទេសថៃ និងប្រទេសកម្ពុជា។ គម្រោងចំនួនពីរកំពុងសាងសង់នាពេលបច្ចុប្បន្ន ហើយគម្រោងផ្សេងទៀតកំពុងស្ថិតនៅដំណាក់កាលខុសៗគ្នានៃការសិក្សា ដែលធ្វើឡើងដោយក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន ក្រោមកិច្ចព្រមព្រៀង ដែលត្រូវបានចុះហត្ថលេខាជាមួយប្រទេសជាសមាជិកនៃគណៈកម្មការទន្លេមេគង្គ (MRC)។

- **ទន្លេមេគង្គ គឺជាច្រក សម្រាប់ដឹកជញ្ជូនរាប់ពាន់ឆ្នាំមកហើយ។** ក្នុងតំបន់អាងទន្លេមេគង្គ ខ្សែទឹកខាងក្រោម គេអាចធ្វើនាវាចរក្នុងទន្លេមេគង្គ និងដៃទន្លេធំៗបានក្នុងរដូវដែលទឹកមានជម្រៅជ្រៅ (ប្រមាណជា ៨ ខែក្នុងមួយឆ្នាំ) លើកលែងតែល្បាក់ខោន ប្រវែង ១៤ គីឡូម៉ែត្រនៅភាគខាងជើងនៃព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសឡាវ ដែលគេមិនអាចឆ្លងកាត់បាន។

- **បច្ចុប្បន្ននេះ ការធ្វើពាណិជ្ជកម្មតាមដងទន្លេមេគង្គបន្តមានការរីកចម្រើន** ដោយមានការប៉ាន់ប្រមាណថា មានទំនិញប្រមាណជា ៤.៥០០ ពាន់តោន ត្រូវបានដឹកជញ្ជូន ជារៀងរាល់ឆ្នាំ ចន្លោះពីប្រទេសចិន និងប្រទេសថៃ។ នៅតំបន់ដីសណ្តរទន្លេមេគង្គ ដែលស្ថិតក្នុងប្រទេសវៀតណាមវិញ ក្នុងចំណោមទំនិញសរុប ដូចជា អង្ករ សម្ភារសំណង់ និងទំនិញប្រើប្រាស់នានា ៧០% ត្រូវបានគេដឹកជញ្ជូនតាមផ្លូវទឹក។ ក្នុងប្រទេសឡាវ ទូកតូចៗត្រូវបានប្រើប្រាស់ជាចម្បង ដើម្បីដឹកជញ្ជូនកសិផល និងសម្ភារសំណង់ទៅ និងមកពីតំបន់នានា ដែលគេអាចទៅដល់បានតែតាមទន្លេ។ នាវាដែលអាចបើកបានក្នុងទន្លេ និងសមុទ្រ ធ្វើចរាចរពីកំពង់ផែទីក្រុងភ្នំពេញ ប្រទេសកម្ពុជា និងក្នុងតំបន់ដីសណ្តទន្លេមេគង្គ។

- **ការកើនឡើងនូវសីតុណ្ហភាព និងកម្ពស់ទឹកភ្លៀង ដែលគេមិនអាចព្យាករណ៍ដឹងមុនបាន កំពុងតែធ្វើឲ្យមានគ្រោះរាំងស្ងួតនៅតំបន់មួយចំនួន និងគ្រោះទឹកជំនន់នៅតំបន់មួយចំនួនទៀត។** នៅក្នុងសកលលោកទាំងមូល ទសវត្សចុងក្រោយនេះ គឺជាទសវត្សរ៍ដែលមានសីតុណ្ហភាពក្តៅជាងគេ មិនធ្លាប់មានកន្លងមក។ ការសិក្សានានាបានព្យាករណ៍ថា កម្ពស់ទឹកភ្លៀងប្រចាំឆ្នាំ ជាមធ្យម នឹងកើនឡើងប្រមាណ ១២០ ម.ម។ ការកើនឡើងនូវកម្ពស់ទឹកសមុទ្រកំពុងបង្កើនបរិមាណទឹកប្រៃ ជ្រាបចូលទៅក្នុងប្រព័ន្ធអេកូឡូហ្ស៊ី ដែលកំពុងតែមានភាពផុយស្រួយរួចទៅហើយ និងដីស្រែចម្ការរបស់ប្រជាពលរដ្ឋនៅតំបន់ដីសណ្តទន្លេមេគង្គ ដែលជាតំបន់ផលិតស្បៀងអាហារដ៏សំខាន់មួយនៃតំបន់នេះ។ ទឹកសមុទ្ររបស់ពិភពលោក កើនកម្ពស់ជាមធ្យម ៣ ម.ម ក្នុងមួយឆ្នាំ ដែលបង្កការគំរាមកំហែងធ្វើឱ្យជន់លិចតំបន់មួយភាគបីនៃតំបន់ដីសណ្តទន្លេមេគង្គនៅសតវត្សរ៍នេះ បង្កការខូចខាតដល់ផលិតភាពកសិកម្ម និងអាចធ្វើឱ្យប្រជាពលរដ្ឋរាប់លាននាក់បាត់បង់ទីលំនៅ។

- **ការខាតបង់ជាប្រចាំឆ្នាំ គិតជាមធ្យមដោយសារគ្រោះទឹកជំនន់ ក្នុងតំបន់អាងទន្លេមេគង្គមានចន្លោះពី ៦០ ទៅ ៧០ លានដុល្លារ** ខណៈពេលដែលផលជាវិជ្ជមានវិញ ពោលគឺតម្លៃជាប្រចាំឆ្នាំគិតជាមធ្យមនៃផលដែលបានពីទឹកជំនន់មានប្រមាណពី ៨-១០ ពាន់លានដុល្លារ។ តំបន់អាងទន្លេនេះ ងាយរងគ្រោះដោយសារផលប៉ះពាល់ជាច្រើន ដែលបង្កឡើងដោយសារការប្រែប្រួលអាកាសធាតុ ដូចជា កំណើនសីតុណ្ហភាពគិតជាមធ្យមប្រមាណ ០,៨ អង្សាសេត្រឹមឆ្នាំ ២០៣០ ក៏ដូចជាការកើនឡើងនូវកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំប្រមាណ ១២០ ម.ម ក្នុងតំបន់នេះ។

- **ផ្ទៃដីប្រមាណ ៦០% នៃតំបន់អាងទន្លេមេគង្គ គឺជាតំបន់វាលទំនាបត្រូពិច ដែលជាតំបន់មានប្រជាពលរដ្ឋរស់នៅច្រើនជាងគេ** និងជាតំបន់ដែលមានដែនជម្រកចម្រុះធំទូលំទូលាយសម្រាប់វារីសត្វ ដែលអាចផ្តល់ការគាំទ្រដល់ពពួកសត្វជាច្រើន ទាំងសត្វក្នុងធម្មជាតិ ទាំងសត្វចិញ្ចឹម។

- **ដោយសារតែប្រជាពលរដ្ឋមួយភាគបួនក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោមរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ជាធម្មតា វិស័យកសិកម្ម គឺជាជម្រើសមួយក្នុងចំណោមជម្រើសដំបូងៗគេ** ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ តាមរយៈការផ្តល់នូវមុខរបរចិញ្ចឹមជីវិតកាន់តែល្អប្រសើរជាងមុន និងការកាត់បន្ថយភាពក្រីក្រ។ តំបន់នេះគឺជាប្រភពមួយក្នុងចំណោមប្រភពសំខាន់ៗនៃស្បៀងអាហារ និងចំណូលសម្រាប់ប្រជាពលរដ្ឋប្រមាណជា ៦០% ក្នុងតំបន់។ កសិករក្នុងតំបន់អាងទន្លេមេគង្គ ផលិតអង្ករក្នុងបរិមាណគ្រប់គ្រាន់ ដើម្បីផ្តល់ជាស្បៀងអាហារដល់ប្រជាពលរដ្ឋ ៣០០ លាននាក់ក្នុងមួយឆ្នាំ។ បើទោះបីជាតម្រូវការស្បៀងក្នុងស្រុកនឹងមានការកើនឡើង ជាពិសេសក្នុងប្រទេសកម្ពុជា និងប្រទេសឡាវ យ៉ាងណាក៏ដោយ គេរំពឹងថាស្បៀងដែលបានពីការធ្វើកសិកម្មក្នុងតំបន់នេះ អាចបំពេញតម្រូវការក្នុងរយៈពេលមធ្យមបាន។ ប៉ុន្តែការធានាសន្តិសុខស្បៀង សម្រាប់ទាំងអស់គ្នានឹងក្លាយជាបញ្ហាប្រឈមសម្រាប់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដោយសារគ្រោះទឹកជំនន់ និងបណ្តាញផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធក្រោយប្រមូលផល ដែលនៅមានលក្ខណៈអន់ខ្សោយនៅឡើយ។ ប្រទេសថៃទំនងជាបន្តជាប្រទេសនាំចេញអង្ករធំមួយ ប៉ុន្តែប្រទេសវៀតណាមទំនងជាត្រូវការយកអតិរេកអង្ករដែលកំពុងនាំចេញបច្ចុប្បន្ននេះ ទៅប្រើប្រាស់ក្នុងប្រទេសរបស់ខ្លួនទៅវិញ។

- តំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោមមានទីតាំងធារាសាស្ត្រជាង ១២.៥០០ កន្លែង រាប់បញ្ចូលទាំងគម្រោងធារាសាស្ត្រខ្នាតតូច និងខ្នាតធំ។ ផ្ទៃដីកសិកម្មតិចជាង ១០% ទទួលបានការស្រោចស្រពនៅរដូវប្រាំង។ **ការធ្វើពិធកម្មដំណាំ គឺជាយុទ្ធសាស្ត្រដែលអាចផ្តល់នូវប្រយោជន៍ ដើម្បីឱ្យការធ្វើកសិកម្មកាន់តែទទួលបានលទ្ធផលល្អប្រសើរជាងមុន។** ដោយសារដំណាំដែលមានតម្លៃខ្ពស់

ច្រើនត្រូវការទឹកតិចជាងស្រូវ ការដាំដំណាំដទៃទៀតអាចបង្កើនផលិតភាពទឹក។ ការធ្វើបែបនេះក៏អាចជួយទប់ទល់ជាមួយនឹងកំណើនតម្រូវការស្បៀង និងអាចជួយពង្រីកប្រភពចំណូលរបស់កសិករផងដែរ។ វាលស្រែផលិតស្បៀង ប៉ុន្តែវាលស្រែទាំងនេះក៏បំពេញមុខងារដ៏មានប្រយោជន៍ផ្សេងទៀត ដូចជា ការកាត់បន្ថយទឹកជំនន់ ការបឺតយកទឹកលើដី ការធ្វើឱ្យមានស្ថិរភាពលំហូរទឹកទន្លេ ការទាញយកទឹកពីប្រព័ន្ធស្រោចស្រពយកមកប្រើប្រាស់ឡើងវិញ ការទប់ការបាក់ដី និងការគ្រប់គ្រងអាកាសធាតុនៅក្នុងតំបន់ផ្ទាល់។ គេក៏អាចបញ្ចូលរបរកសិកម្ម ការនេសាទ និងការចិញ្ចឹមសត្វរួមគ្នា ដើម្បីធ្វើពិពិធកម្មមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋផងដែរ។

###